- ម៉ាស៊ីន ATM ភាគច្រើន
នឹងមានបញ្ជីចំនួនប្រាក់ដកដែល
គេនិយមបំផុត ដូចជា $20, $50, $60, $80 ឬ $100
និងច្រើនទៀត។ ប្រសិនបើចំនួនដែលលោកអ្នកត្រូវការ
មាននៅទីនោះ សូមជ្រើសរើសវា ហើយប្រសិនបើលោក
អ្នកចង់បានចំនួនផ្សេងទៀត សូមរើសយក "other
amount" (ចំនួនផ្សេងទៀត) ហើយវានឹងចេញផ្ទាំង
អេក្រង់មួយ ដែលលោកអ្នកអាចចុចចំនួនទឹកប្រាក់ដែល
លោកអ្នកត្រូវការ។ ដើម្បីចុចបញ្ចូលចំនួន សូមចុចតាម
ដំណើរធម្មតាដូចដែលលោកអ្នកធ្វើ ហើយចំណុចទសភាគ
នឹងចេញមកដោយខ្លួនឯង។ ឧទាហរណ៍ នៅពេលចុច
បញ្ចូល $500 នៅពេលនោះលេខទសភាគនឹងលេចចេញ
មក គឺ .00។ បន្ទាប់មកជ្រើសរើស ENTER (ចូល)។

- ម៉ាស៊ីននឹងសួរបញ្ជាក់សំណើរបស់លោកអ្នក
ហើយនឹងសុំ
ឲ្យលោកអ្នកចុច ENTER ដើម្បីធ្វើកិច្ចការតទៅទៀត។

- ម៉ាស៊ីននឹងសួរថាតើលោកអ្នកចង់បានបង្កាន់ដៃដែរឬ

ទេ
ដែលនឹងប្រាប់លោកអ្នកអំពីចំនួនទឹកប្រាក់លោកអ្នកមាន
ក្នុងគណនីរបស់លោកអ្នក ក្រោយពីការដកប្រាក់នេះរួច។
ប្រសិនបើលោកអ្នកចង់បានបង្កាន់ដៃ សូមជ្រើសរើស
"yes" (បាទ/ចាស) ឬប្រសិនបើលោកអ្នកពុំចង់បានទេ
សូមជ្រើសរើស "no" (ទេ)។

- ពេលនោះ ម៉ាស៊ីននឹងចាត់ចែងសំណើរបស់លោកអ

្នក
ហើយបន្ទាប់មក ប្រគល់ប័ណ្ណរបស់លោកអ្នកមកវិញ
បន្ទាប់មកប្រាក់ និងទីបញ្ចប់គឺបង្កាន់ដៃ ប្រសិនបើ

ដើម្បីដាក់ប្រាក់ នៅលើផ្ទាំងអេក្រង់សម្រាប់
ជ្រើសរើស សូមជ្រើសរើសយក "deposit"
(ដាក់ប្រាក់)។ បន្ទាប់មក វាយបញ្ចូល
ចំនួនទឹកប្រាក់ និងរៀបចំមូលប្បទានប័ត្រ
ឬប្រាក់រួចស្រេចដាក់ក្នុង "deposit
envelop" (ស្រោមសំបុត្រដាក់ប្រាក់)
ហើយសិកស្រោមសំបុត្រទៅក្នុងរន្ធសិក
ដាក់ប្រាក់ នៅពេលវាបើកឡើង។

**សូមចាំថា ពុំមែនម៉ាស៊ីន ATM
ទាំងអស់អនុញ្ញាតឲ្យលោកអ្នក
ដាក់ប្រាក់ឡើយ!**

An Australian Government Initiative
The Heights Community Services — Connecting Communities
Seniors Safety Strategy



# សេចក្តីណែនាំរបស់លោកអ្នក សម្រាប់ការប្រើម៉ាស៊ីន EFTPOS និង ATM

# កិច្ចការរបស់ EFTPOS

EFTPOS (ការបង់ប្រាក់តាមអេឡិចត្រូនិចនៅកន្លែងលក់) អាចប្រើបាន ប្រសិនបើលោកអ្នកពុំមានប្រាក់ជាប់ខ្លួនពេលទៅផ្សារទិញឥវ៉ាន់។ ដោយការវាយបញ្ចូលលេខ PIN របស់លោកអ្នក លោកអ្នកផ្ដល់លទ្ធភាពឲ្យហាងទំនិញ ដកចំនួនប្រាក់ដែលកំណត់ ចេញពីគណនីរបស់លោកអ្នក។ មុនពេលលោកអ្នកចាប់ផ្ដើម សូមកត់សម្គាល់ថាហាងទំនិញជាច្រើនបានកម្រិតចំនួនប្រាក់តិចបំផុត $10 ដើម្បីប្រើ EFTPOS ដែលមានន័យថាលោកអ្នកចាំបាច់ត្រូវទិញទំនិញអស់ប្រាក់យ៉ាងតិចបំផុត $10 ទើបអាចប្រើ EFTPOS បាន។ ប្រសិនបើលោកអ្នកចំណាយតិចជាងចំនួននេះ សូមបង់សាច់ប្រាក់តែប៉ុណ្ណោះ ឬប្រសិនបើលោកអ្នកពុំមានប្រាក់ជាប់ខ្លួនទេ សូមធ្វើដំណើរទៅកាន់ម៉ាស៊ីន ATM ដែលនៅជិតជាងគេ ហើយដកប្រាក់នៅទីនោះ។

- ស៊ិកបញ្ចូលប័ណ្ណរបស់លោកអ្នក តាមរបៀបដូចបានបង្ហាញ។
- ជ្រើសរើសប្រភេទគណនី ថាតើជា Savings (គណនីសន្សំ) Cheque (មូលប្បទានប័ត្រ) ឬ Credit (ឥណទាន)។
- បន្ទាប់មក លោកអ្នកនឹងត្រូវចុចលេខ PIN របស់លោកអ្នក ហើយចុច ENTER។
- ការដកប្រាក់នឹងកើតមានឡើង។
- ពេលការនេះកើតឡើងហើយ សញ្ញា "approved sign" (ហត្ថលេខាបានយល់ព្រម) នឹងលេចឡើង ហើយកិច្ចការបានបំពេញចប់សព្វគ្រប់ ហើយអ្នកលក់នឹងហុចបង្កាន់ដៃមកឲ្យលោកអ្នក។
- ប្រសិនបើលោកអ្នកចង់ប្រើឥណទាន (credit) នៅដំណាក់កាលជ្រើសរើស សូមជ្រើសរើស credit ហើយម៉ាស៊ីន ឬអ្នកលក់នឹងសួរថាតើលោកអ្នកចង់ប្រើលេខ PIN ឬចុះហត្ថលេខា ឬទេ ចូរជ្រើសរើសយកជំរើសរបស់លោកអ្នក។
- ចំពោះការប្រើលេខ PIN

សូមធ្វើដូចសេចក្ដីណែនាំខាងលើ។

- ចំពោះការប្រើហត្ថលេខា អ្នកលក់នឹងបោះពុម្ពបង្កាន់ដៃ ហើយនឹងឲ្យលោកអ្នកចុះហត្ថលេខានៅចំពោះមុខគេ ក្នុងខណៈដែលគេពិនិត្យបញ្ជាក់ហត្ថលេខារបស់លោកអ្នក ដោយធ្វើការប្រៀបធៀបវាជាមួយហត្ថលេខាលើខ្នងប័ណ្ណរបស់លោកអ្នក។
- អ្នកលក់នឹងបោះពុម្ពបង្កាន់ដៃដោយឡែកមួយទៀតសម្រាប់លោកអ្នក។
- កិច្ចការបានបំពេញចប់សព្វគ្រប់!




# កិច្ចការរបស់ម៉ាស៊ីន ATM

ម៉ាស៊ីន ATM (ម៉ាស៊ីនដក / ដាក់ប្រាក់ជាស្វ័យប្រវត្តិ) អនុញ្ញាតឲ្យលោកអ្នកធ្វើការដក ឬដាក់ប្រាក់សាមញ្ញ ដោយពុំចាំបាច់ចូលទៅក្នុងធនាគារផ្ទាល់ឡើយ។ ជាមួយម៉ាស៊ីន ATM លោកអ្នកអាចដកប្រាក់ ដាក់ប្រាក់ ឬមូលប្បទានប័ត្រ និងឆែកមើលចំនួនទឹកប្រាក់របស់លោកអ្នកដែលមាននៅក្នុងគណនី។ តទៅនេះគឺជាគោលការណ៍ណែនាំសម្រាប់ការដកប្រាក់។

- ស៊ិកបញ្ចូល keycard ឬ debit card (ប័ណ្ណឥណពន្ធ) របស់លោកអ្នកឲ្យត្រូវតាមរបៀប (ម៉ាស៊ីន ATM ភាគច្រើននឹងមាន រូបភាពដើម្បីបង្ហាញលោកអ្នកអំពីរបៀបស៊ិកបញ្ចូលប័ណ្ណរបស់លោកអ្នក)។
- បន្ទាប់មក ម៉ាស៊ីននឹងសួរលោកអ្នកអំពីលេខ PIN (លេខអត្តសញ្ញាណផ្ទាល់ខ្លួន) របស់លោកអ្នក។ ចុចបញ្ចូលលេខនេះ ហើយបន្ទាប់មកចុច ENTER ។
- បន្ទាប់មក ម៉ាស៊ីននឹងសួរថាតើលោកអ្នកចង់ធ្វើអ្វី (តាមរយៈផ្ទាំងអេក្រង់សម្រាប់ជ្រើសរើស) ថាតើចង់ដកប្រាក់ ដាក់ប្រាក់ ឬឆែកមើលចំនួនទឹកប្រាក់ដែលលោកអ្នកមាននៅសល់។ ម៉ាស៊ីននឹងសុំឲ្យលោកអ្នកជ្រើសយកជំរើសដែលលោកអ្នកចង់បាន។ ដូច្នេះ ដើម្បីដកប្រាក់ សូមចុច "withdraw cash" (ដកប្រាក់)។

.....បន្ត